## ១. ការគ្រប់គ្រងសេដ្ឋកិច្ច និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

ស្របតាមផែនការយុទ្ធសាស្ត្រថវិកា២០២១-២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គោលបំណងគោលនយោបាយទី១. "ការគ្រប់គ្រងសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ" មានកម្មវិធីចំនួន២ ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយនេះ។

### ១.១. ការគ្រប់គ្រងសេដ្ឋកិច្ច

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានគោលនយោបាយ និងអគ្គលេខាធិការដ្ឋានគណៈកម្មការផលិតភាពសេដ្ឋកិច្ចកម្ពុជា។ អគ្គនាយកដ្ឋានគោលនយោបាយមានមុខងារសំខាន់ៗ ក្នុងការរៀបចំ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, តាមដាន និងវាយតម្លៃនិន្នាការសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក ក្នុងកម្រិតវិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចូលរួមចំណែកក្នុងការងារពាក់ព័ន្ធដល់ការរៀបចំគោលនយោបាយ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុក្រៅប្រទេស និងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ ក្នុងតំបន់ និងពិភពលោក[1]។ រីឯអគ្គលេខាធិការដ្ឋានគណៈកម្មការផលិតភាពសេដ្ឋកិច្ចកម្ពុជាផ្តោតលើកិច្ចការរដ្ឋបាលនិងការងារបច្ចេកទេសសិក្សាស្រាវជ្រាវ សម្រាប់គាំទ្រកិច្ចដំណើរការរបស់គណៈកម្មការផលិតភាពសេដ្ឋកិច្ចកម្ពុជា។ ជាលទ្ធផលក្នុងឆមាសទី១ ឆ្នាំ២០២២ អង្គភាពទាំងពីរបានអនុវត្ត និងទទួលបានវឌ្ឍនភាពដូចមានក្នុងរបាយការណ៍ខាងក្រោម៖

- រៀបចំកម្រងទិន្នន័យស្តីពីចំណូលចរន្តថវិការដ្ឋ និងការប្រៀបធៀបចំណូល-ចំណាយនឹងប្រទេសជិតខាង
- ធ្វើបច្ចុប្បន្នភាពឯកសារព្រាងនៃគោលនយោបាយសារពើពន្ធជំរុញការប្រើប្រាស់រថយន្តភាតរបរិស្ថាន
- រៀបចំរបាយការណ៍ឃ្លាំមើលសេដ្ឋកិច្ចប្រចាំត្រីមាសទី៤ ឆ្នាំ ២០២១
- រៀបចំការសិក្សាស្តីពីរចនាសម្ព័ន្ធនៃចំណូលតាមប្រភេទពន្ធតាមបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍
- ឯកសារទស្សនាទានស្តីពីការសិក្សាអំពីផលប៉ះពាល់នៃការកើនឡើងថ្លៃជី ចំណីសត្វ និងប្រេងលើវិស័យកសិកម្ម និងអាហារមូលដ្ឋាន




សន្និសីទជាន់ខ្ពស់ ស្តីពី "ហិរញ្ញប្បទានប្រកបដោយចីរភាព៖ ការគៀរគរហិរញ្ញប្បទានសម្រាប់ការស្តារសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩" ថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២២

- រៀបចំកែសម្រួលកម្រងសំណួរសម្រាប់ការស្ទង់មតិ ជាមួយវិស័យឯកជនសម្រាប់ដំណើរការក្របខ័ណ្ឌវាយតម្លៃពាក់កណ្តាលអាណត្តិយុទ្ធសាស្ត្រគៀរគរចំណូល២០១៩-២០២៣ លើការអនុវត្តគោលនយោបាយសារពើពន្ធនិងផ្នែកទំនើបកម្មរដ្ឋបាលពន្ធគយ
- រៀបចំក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការតម្រង់ទិសអាទិភាពគោលនយោបាយ និងពង្រឹងកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ក្នុងគន្លងនៃប្រក្រតីភាពថ្មីឆ្នាំ២០២៣ និងឆ្នាំបន្ទាប់
- រៀបចំកម្រងទិន្នន័យអំពី ការប្រមូលចំណូលចរន្ត ដល់ក្រុមការងារមូនិធិរូបិយវត្ថុអន្តរជាតិ
- រៀបចំលិខិតឆ្លើយតបការស្នើសុំរបស់ IMF លើទិន្នន័យការប្រែប្រួលអាកាសធាតុរបស់កម្ពុជា

---

[1] មាត្រា ១២ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- អនុវត្តគម្រោងសិក្សាស្រាវជ្រាវបែបវិទ្យាសាស្រ្តចំនួន ២ គឺ÷
    - គម្រោងទី១ ស្តីពី “ការវិភាគ និងវាយតម្លៃអំពីតំណភ្ជាប់ពាណិជ្ជកម្ម និងផលិតភាពសេដ្ឋកិច្ចនៅកម្ពុជា” ដែលមានគោលបំណងដើម្បី ក.សិក្សា និងវាយតម្លៃអំពីឥទ្ធិពល និងផលប៉ះពាល់ នៃយុទ្ធសាស្រ្តពាណិជ្ជកម្ម ដែលមានស្រាប់ទៅលើផលិតភាពសេដ្ឋកិច្ចនៅកម្ពុជា, ខ. កំណត់យុទ្ធសាស្រ្តជំរុញផលិតភាព ដើម្បីបង្កើនសមត្ថភាព និងលទ្ធភាពរបស់កម្ពុជាក្នុងការចាប់យក និងបង្កើនខ្សែច្រវាក់តម្លៃ និង គ. អភិវឌ្ឍយុទ្ធសាស្រ្តសម្រាប់កែលម្អតំណភ្ជាប់រវាងពាណិជ្ជកម្ម និងផលិតភាពសេដ្ឋកិច្ច
    - គម្រោងទី២ ស្តីពី “បច្ច័យនៃការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល ក្នុងការលើកកម្ពស់ និងធ្វើបរិវត្តកម្មលើសមត្ថភាព និងលទ្ធភាពរបស់កម្ពុជា សម្រាប់ពង្រីកទំហំសេដ្ឋកិច្ច និងជំរុញពិពិធកម្មសេដ្ឋកិច្ច” ដែលមានគោលបំណងដើម្បី ក. ពិនិត្យ និងវិភាគអំពីទំនាក់ទំនងរវាងសេដ្ឋកិច្ចឌីជីថល ជាមួយផលិតភាពសេដ្ឋកិច្ច និងពិពិធកម្មសេដ្ឋកិច្ច និង ខ. អភិវឌ្ឍយុទ្ធសាស្រ្តសម្រាប់ពង្រឹងតំណភ្ជាប់រវាងផលិតភាពសេដ្ឋកិច្ច និងពិពិធកម្មសេដ្ឋកិច្ច។

## ១.២. ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារ ,អគ្គលេខាធិការដ្ឋានល្បែងពាណិជ្ជកម្មកម្ពុជា, និយ័តករធានារ៉ាប់រងកម្ពុជា, និយ័តករមូលបត្រកម្ពុជា, និយ័តករបរធនបាលកិច្ច,និយ័តករអាជីវកម្មអចលនទ្រព្យ និងបញ្ចាំ អង្គភាពសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារ ដែលទើបបង្កើត និងបំបែកចេញពីអគ្គនាយកឧស្សាហកម្មហិរញ្ញវត្ថុ និយ័តករគណនេយ្យ និងសវនកម្ម លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ អង្គភាពដែលទើបបំបែកពីឧស្សាហកម្មហិរញ្ញវត្ថុ មានមុខងារក្នុងការគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ អាជីវកម្មភ្នាល់គ្រប់ប្រភេទ អាជីវកម្មអចលនទ្រព្យនិងចូលរួមប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។ និយ័តករគណនេយ្យ និងសវនកម្ម បំពេញបេសកកម្មគ្រប់គ្រងអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម។ សម្រាប់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមវិញ បំពេញមុខងារជាសេនាធិការគោលនយោបាយ និងបច្ចេកទេសរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។ ជាលទ្ធផល អង្គភាពអស់ខាងលើបានអនុវត្តនិងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

### ១.២.១. វិស័យល្បែងពាណិជ្ជកម្ម

- បានរៀបចំលិខិតស្តីពីការបង់កម្រៃសិទ្ធិផ្តាច់មុខប្រចាំឆ្នាំ២០២១ របស់ក្រុមហ៊ុន១ ដែលមានទឹកប្រាក់សរុបចំនួន ៦០០,០០០ដុល្លារ
- បានចេញលិខិតរំលឹកស្តីពីការបង់កម្រៃអាជ្ញាបណ្ណ ប្រចាំឆ្នាំ២០២២ កម្រៃផ្សេងៗ និងការបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូជូនរដ្ឋប្រចាំឆ្នាំ២០២០ ឆ្នាំ២០២១ និងប្រចាំខែមករា ខែកុម្ភៈ ខែមីនា និងខែមេសា ឆ្នាំ២០២២ របស់កាស៊ីណូមួយកន្លែង នៅរាជធានីភ្នំពេញ
- គិតត្រឹមខែមិថុនា ឆ្នាំ២០២២នេះ ចំណូលពីកម្រៃផ្សេងៗរបស់ អ.គ.ល.ក. មានសរុបចំនួន ១៤២,២០២.១១លានរៀល
- បានរៀបចំផែនការបណ្តុះបណ្តាលស្តីពីការអនុវត្តលទ្ធផលជាក់ស្តែងទី១១ ឆ្នាំ២០២២ ពាក់ព័ន្ធនឹងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

- បានរៀបចំលិខិតរំលឹកដល់ប្រតិបត្តិករ និង/ឬកម្មសិទ្ធិករកាស៊ីណូចំនួន២២ក្រុមហ៊ុន ដែលមិនទាន់បំពេញចំណូលកាតព្វកិច្ចពីល្បែងជូនរដ្ឋប្រចាំខែ ពីខែមករា ដល់ខែឧសភា ឆ្នាំ២០២២




កិច្ចប្រជុំគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា (គ.ល.ក.) លើកទី៤ អាណត្តិទី១ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ តាមរយៈប្រព័ន្ធអនឡាញ

- ចុះត្រួតពិនិត្យ និងវាយតម្លៃដល់ទីកន្លែងលើពាក្យស្នើសុំអាជ្ញាបណ្ណ របស់ក្រុមហ៊ុនកាស៊ីណូ ចំនួន១២៥ និងក្រុមហ៊ុនល្បែងផ្សងសំណាង ចំនួន ២២
- បានពិនិត្យបែបបទ និងវាយតម្លៃលើការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណសម្រាប់ឆ្នាំ២០២២ របស់ប្រតិបត្តិករ និង/ឬកម្មសិទ្ធិករកាស៊ីណូ និងល្បែងផ្សងសំណាង ដោយដំណាក់កាលទី១ គ.ល.ក. បានសម្រេចផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុនកាស៊ីណូ ១៣
- គិតត្រឹមខែមិថុនា ឆ្នាំ២០២២ ចំណូលប្រមូលបានពីចំណូលកាតព្វកិច្ចពីល្បែងសរុបមានចំនួន ១៤,៥៧៤.៤៥ លានរៀល ស្មើនឹង ៩.៦៥% នៃផែនការ ក្នុងនោះមាន÷
    - ចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូមានចំនួន ៣,១១៦,៥៥៥.៩៨ដុល្លារ ស្មើនឹង ១២,៦៤១.៣៨លានរៀល ស្មើនឹង ៨.៥% ធៀបនឹងផែនការ(១៤៨,៥៦៦.៨លានរៀល)
    - ចំណូលកាតព្វកិច្ចពីល្បែងផ្សងសំណាង (ឆ្នោត-ឡូតូ)មានចំនួន ១,៩៣៣.០៧លានរៀល ស្មើនឹង ៨២.១៨% ធៀបនឹងផែនការ(២,៣៥២.៨លានរៀល)។

### ១.២.២. វិស័យមូលបត្រនៅកម្ពុជា

- បានលុបចោលអាជ្ញាបណ្ណភ្នាក់ងារក្រុមហ៊ុនមូលបត្រ និងបុគ្គលទទួលស្គាល់គុណវុឌ្ឍិចំនួន ៧ ករណី
- បានចេញលិខិតតម្រូវពាក់ព័ន្ធនឹងកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុចំនួន ៦៧ លើក
- បានបញ្ចប់របាយការណ៍ស្តីពីលទ្ធផលចុះត្រួតពិនិត្យដល់ទីកន្លែងចំនួន ៦ ករណី
- បានផ្តល់លេខអត្តសញ្ញាណវិនិយោគិនចំនួន ១.៥៧៦ វិនិយោគិន
- បានបន្តសុពលភាពលេខអត្តសញ្ញាណវិនិយោគិចំនួន ៧៣២ លេខអត្តសញ្ញាណវិនិយោគិន
- បានធ្វើបច្ចុប្បន្នភាពព័ត៌មានលេខអត្តសញ្ញាណវិនិយោគិនចំនួន ១០៨ លេខអត្តសញ្ញាណវិនិយោគិន
- បានបញ្ចប់ការរៀបចំ និងបានផ្សព្វផ្សាយព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ២០២២
- បានបញ្ចប់ការរៀបចំ និងបានផ្សព្វផ្សាយព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ២០២២
- បានផ្សព្វផ្សាយពីកិច្ចគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ តាមរយៈវគ្គបណ្តុះបណ្តាលគុណវុឌ្ឍិ និងបន្តគុណវុឌ្ឍិចំនួន ១០ លើក

- បានអនុម័តរួចរាល់នូវអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- បានរៀបចំរួចរាល់ សៀវភៅនីតិវិធីប្រតិបត្តិការស្តង់ដារ ស្តីពីការស៊ើបអង្កេត ការចោទប្រកាន់ និង ការពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្នុងវិស័យមូលបត្រ
- បានរៀបចំសេចក្តីសម្រេចក្រុមការងារវាយតម្លៃហានិភ័យសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យក្នុងវិស័យមូលបត្រ។




ព្រឹត្តបត្រវិនិយោគ និងការវិនិយោគលេខ៩ ឆ្នាំ២០២២

### ១.២.៣. វិស័យបរធនបាលកិច្ច

- បានរៀបចំសេចក្តីព្រាងស្រាវជ្រាវនិន្នាការអភិវឌ្ឍវិស័យបរធនបាលកិច្ចរបស់ប្រទេសនៅក្នុងតំបន់អាស៊ាន
- បានរៀបចំរបាយការណ៍កិច្ចប្រជុំបកស្រាយ និងបំភ្លឺបន្ថែមលើករណីរបាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំ២០២១ របស់ CCB
- បានរៀបចំរបាយការណ៍ និងចេញលិខិតបកស្រាយ និងបំភ្លឺបន្ថែមលើករណីរបាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំ២០២១ របស់ HFT


លេខ ១៣ ចេញផ្សាយថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

ព្រឹត្តបត្រព័ត៌មានប្រចាំខែមិថុនា ឆ្នាំ២០២២

និយ័តករបរធនបាលកិច្ច

កិច្ចប្រជុំពិភាក្សាការងារជាមួយសមាគមឧបត្ថម្ភកម្ពុជា (CCC)

www.trustregulator.gov.kh
www.facebook.com/trustregulatorcambodia
(855) 23 237 888

ព្រឹត្តបត្រវិនិយោគ និងការវិនិយោគលេខ៩ ឆ្នាំ២០២២

- បានរៀបចំរបាយការណ៍ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ របស់ ARF
- បានចុះធ្វើអធិការកិច្ចដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់បន្ថែមលើកម្មវិធីចំណាយរបស់ CHC នៅមជ្ឈមណ្ឌលម៉ាឌុកជីវន្ត និងនៅមន្ទីរពេទ្យបង្អែកស្រុកកំពង់ត្រាច ខេត្តកំពត
- បាននិងកំពុងរៀបចំរបាយការណ៍ស្តីពីស្នើសុំពន្យារពេលផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំ២០២១ របស់ SFT
- បានចេញលិខិត និងសេចក្តីសម្រេចស្តីពីការចុះបញ្ជីជាបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រចំនួន១
- បានចេញលិខិត និងសេចក្តីសម្រេចស្តីពីការចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រ ចំនួន ៥ ករណី
- បានចេញវិញ្ញាបនបត្រចុះបញ្ជីបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រ ចំនួន ១ ករណី
- បានចេញវិញ្ញាបនបត្រចុះបញ្ជីប្រតិបត្តិករបរធនបាលកិច្ច ចំនួន ៥ ករណី

- បានធ្វើរបាយការណ៍វាយតម្លៃពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រ ចំនួន ១ ករណី
- បានធ្វើរបាយការណ៍វាយតម្លៃពាក្យស្នើសុំចុះបញ្ជីជាបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រចំនួន១ ករណី
- បានធ្វើរបាយការណ៍វាយតម្លៃពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រ ចំនួន ១ ករណី
- បានធ្វើរបាយការណ៍ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីធ្វើនិយ័តកម្មបរធនបាល ចំនួន ១ករណី
- បានធ្វើរបាយការណ៍ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីធ្វើនិយ័តកម្មបរធនបាល និងបច្ចុប្បន្នកម្មលើលិខិតបរធនបាលកិច្ច ចំនួន ១ ករណី។

### ១.២.៤. វិស័យធានារ៉ាប់រងនៅកម្ពុជា

- បានដាក់សេចក្តីព្រាងប្រកាសស្តីពីការគណនាទុនបម្រុងបច្ចេកទេសសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ជូនក្រុមប្រឹក្សាកម្រិតបច្ចេកទេស អ.ស.ហ ដើម្បីពិនិត្យលើខ្លឹមសារសេចក្តីព្រាងប្រកាសនេះឱ្យបានគ្រប់ជ្រុងជ្រោយ
- បានដាក់សេចក្តីព្រាងប្រកាសស្តីពីគោលការណ៍ណែនាំលើការវិនិយោគរបស់ក្រុមហ៊ុនធានារ៉ាប់រង ជូនក្រុមកម្រិតបច្ចេកទេស អ.ស.ហ ដើម្បីពិនិត្យលើខ្លឹមសារសេចក្តីព្រាងប្រកាសនេះឱ្យបានគ្រប់ជ្រុងជ្រោយ
- បានរៀបចំកិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាង "ផែនការអភិវឌ្ឍន៍ស្ថាប័ន ២០២១-២០២៥ របស់និយ័តករធានារ៉ាប់រងកម្ពុជា"
- បានរៀបចំសេចក្តីព្រាងឯកសារទស្សនទានស្តីពីផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើវិស័យធានារ៉ាប់រងនៅកម្ពុជា និងបានស្រាវជ្រាវបន្ថែមលើឯកសារពាក់ព័ន្ធ
- បានរៀបចំសេចក្តីព្រាងឯកសារទស្សនទានស្តីពីការឆ្ពោះទៅរកការប្រើប្រាស់យ៉ាងស៊ីជម្រៅនៃបច្ចេកវិទ្យាធានារ៉ាប់រងនៅម្ពុជា ដើម្បីស្នើសុំជំនួយបច្ចេកទេសពីធនាគារពិភពលោកលើបច្ចេកវិទ្យាធានារ៉ាប់រង
- ការកែសម្រួលលើសេចក្តីព្រាងឯកសារទស្សនទាន និងការស្រាវជ្រាវរៀបចំបន្ថែមលើ គម្រោងសិក្សាស្រាវជ្រាវស្តីពី ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើវិស័យធានារ៉ាប់រងនៅកម្ពុជា ដើម្បីរៀបចំជាកម្រងសំណួរ




កម្មវិធីចែករំលែកចំណេះដឹងធានារ៉ាប់រងលេខ ០២២០៦

- រៀបចំសេចក្តីព្រាងឯកសារទស្សនទានស្តីពី ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើវិស័យធានារ៉ាប់រងនៅកម្ពុជា។

### ១.២.៥. វិស័យអចលនវត្ថុ និងបញ្ចាំ

- បានជួបផ្តល់ប្រឹក្សាយោបល់ជាមួយតំណាងគម្រោងដីឡូត៍ចំនួន៨ ក្រុមហ៊ុនដែលធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ, និងរៀបចំចូលរួមប្រជុំផ្ទៃក្នុង ន.អ.ប. ពាក់ព័ន្ធនឹងក្រុមហ៊ុនគម្រោងដីឡូត៍ចំនួន ១៣

- បន្តផ្សព្វផ្សាយដល់ក្រុមហ៊ុនដែលធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ ឱ្យមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍដីឡូត៍ពី ន.អ.ប. និងបានទទួលការទំនាក់ទំនងពីក្រុមហ៊ុនចំនួន ៤៧ ក្រុមហ៊ុនតាមរយៈទូរស័ព្ទសាកសួរព័ត៌មានពីការស្នើសុំអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍដីឡូត៍ពី ន.អ.ប.
- បានត្រួតពិនិត្យ និងរៀបចំសុំណុំឯកសារលើការស្នើសុំអាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈថ្មី/ប្រចាំឆ្នាំ/បន្តសុពលភាព/ផ្លាស់ប្តូរ/បន្ថែម/បញ្ចប់អាជ្ញាបណ្ណនិងវិញ្ញាបនបត្រវិជ្ជាជីវៈ របស់ក្រុមហ៊ុនប្រកបអាជីវកម្មសេវាកម្មផ្តល់សេវាកម្មវាយតម្លៃ និងអចលនវត្ថុ ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច ជូន ១២១ ក្រុមហ៊ុន
- បានត្រួតពិនិត្យការស្នើសុំផ្លាស់ប្តូរទីតាំងអាជីវកម្ម, ភាគហ៊ុនិក និង/ឬសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ១៣ ក្រុមហ៊ុន
- បានរៀបចំលិខិតជូនដំណឹងស្តីពីការផាកពិន័យក្រុមហ៊ុន/សហគ្រាសសរុបចំនួន ៣៨ក្រុមហ៊ុន÷ (ក្រុមហ៊ុនសេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុចំនួន ១០ ក្រុមហ៊ុន, ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុចំនួន ០៣ ក្រុមហ៊ុន និងក្រុមហ៊ុន/សហគ្រាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទានចំនួន ២៥ ក្រុមហ៊ុន)
- បានពិនិត្យ និងផ្តល់យោបល់លើកិច្ចសន្យាទិញ-លក់ដីឡូត៍ចំនួន ០៥ ក្រុមហ៊ុន។

## ១.៣. ការងារគាំពារសង្គមកម្ពុជា

- បានរៀបចំសេចក្តីព្រាងឯកសារទស្សនទានស្តីពីសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម
- បានពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារចំនួន ១៣ច្បាប់ និងរបាយការណ៍នៃការសិក្សាពីយន្តការដោះស្រាយបណ្តឹង ឬវិវាទក្នុងប្រព័ន្ធគាំពារសង្គម ដែលរៀបចំដោយទីប្រឹក្សាជាន់ខ្ពស់
- បានរៀបចំរបាយការណ៍ពីការសិក្សាស្រាវជ្រាវស្តីពីនិមាបនកម្មគតិយុត្ត ក្នុងប្រព័ន្ធគាំពារសង្គមរវាងទីប្រឹក្សាជាន់ខ្ពស់តំណាងអង្គការអន្តរជាតិខាងការងារ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- បានពិនិត្យរបាយការណ៍បឋមលើឯកសារទស្សនទាននិមាបនកម្មគតិយុត្ត ក្នុងប្រព័ន្ធគាំពារសង្គមរបស់ទីប្រឹក្សាជាន់ខ្ពស់ ចំនួន ១៤ ឯកសារ



ការបើកប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

- បានបញ្ចប់ការពិនិត្យ និងកែសម្រួលលើពង្រាង “ក្របខណ្ឌកញ្ចប់គ្រួសារ” ជាភាសាខ្មែរ
- បានរៀបចំរបាយការណ៍សង្ខេប គោរពជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ស្តីពីលទ្ធផល នៃការវាយតម្លៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្រោយពេលបិទខ្ទប់សម្រាប់ ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព, ប្រជាពលរដ្ឋនិងគ្រួសារ ប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព, និងគ្រួសារ ប្រជាពលរដ្ឋ ដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩
- បានបញ្ចប់របាយការណ៍សង្ខេបនៃកម្មវិធីវិប្បសនាស្តីពីយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម និងបានលើកជាផែនការសកម្មភាពសម្រាប់អនុវត្តបន្ត
- បានព្រាងឯកសារទស្សនទានបច្ចេកទេស ស្តីពីការអភិវឌ្ឍមុខងារសមកាលកម្មទិន្នន័យដោយស្វ័យប្រវត្តិសម្រាប់ប្រព័ន្ធយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ជាមួយប្រព័ន្ធ PMRS នៃទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល។

### ១.៤. ការងារគណនេយ្យ និងសវនកម្ម

- ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំនេញ ត្រូវបានដាក់អោយប្រើប្រាស់ជាផ្លូវការដំណាក់កាលទី១ (មុខងារស្នើសុំលេខអត្តសញ្ញាណកម្ម, មុខងារជូនដំណឹងពីការប្រើប្រាស់ភាសា)
- ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវបានដាក់ឱ្យប្រើប្រាស់
- ផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យចំនួន២ក្រុមហ៊ុន, បន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មចំនួន៧ក្រុមហ៊ុន, បន្តសិទ្ធិចុះហត្ថលេខារបស់ជនបរទេសចំនួន៩ក្រុមហ៊ុន គណនេយ្យនិងសវនកម្មត្រូវបានធ្វើបច្ចុប្បន្នភាព
- ប្រកាសស្តីពីការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ
- អនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្មបានដាក់ឆ្លងកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករ បានដាក់ឆ្លងកិច្ចពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធដារនិងបានដាក់ឆ្លងកិច្ចប្រជុំជាមួយក្រសួងយុត្តិធម៌



វេទិកាស្តីពីការដាក់បញ្ជូលរបាយការណ៍ហិរញ្ញវត្ថុ តាមប្រព័ន្ធអនឡាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំនេញ

- សេចក្តីព្រាងប្រកាសស្តីពីវិធាន និងនិតីវិធី នការដោះស្រាយបណ្តឹងតវ៉ាចំពោះពិន័យអន្តរការណ៍ និងសេចក្តីព្រាងប្រកាសស្តីពីវិធាននិងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា បានរៀបចំរួចរាល់កម្រិតបឋម។

## ២. ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ

គោលបំណងគោលនយោបាយទី២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺ "ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" ដែលមានកម្មវិធីចំនួន៣។ លទ្ធផលនៃការអនុវត្តក្នុងឆមាសទី១ ឆ្នាំ២០២២ នៃការអនុវត្តនៃគោលបំណងគោលនយោបាយទី២ នេះមានដូចក្នុងរបាយការណ៍ខាងក្រោមនេះ÷

### ២.១. ការកៀរគរចំណូលថវិកាជាតិ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានបេសកកម្មសំខាន់ៗក្នុងនោះ÷ ១.ទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលអាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬនាំចូល ស្របតាមបញ្ញត្តិ ស្តីពីគយ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល ការធ្វើចរាចរ និងការធ្វើសន្និធិទំនិញ ២.ដាក់បទប្បញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំចេញ ឬនាំចូល ៣. ជំរុញការបង្ការ និងបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ ៤.ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ៥. ជំរុញអនុវត្តតាមស្តង់ដារអន្តរជាតិ និងឧត្តមានុវត្តន៍ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យគយ និងការសម្រួលពាណិជ្ជកម្ម ជាពិសេស ការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ និងការធ្វើស្វ័យប្រវត្តិកម្មគយ[2]។ ដោយឡែកអគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មសំខាន់ៗ ក្នុងនោះ ១. ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន

---

[2] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ការផ្ដល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្ដីពីពន្ធដារ ២. អនុវត្តកម្មវិធីចាប់បង្ខំ ដោយធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ អនុវត្តទោសទណ្ឌ តាមការកំណត់ស្ដីពីពន្ធដារ ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្ដីពីពន្ធដារ ៣. ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្ដីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ ៤. ផ្ដល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្ដីពីពន្ធដារ ត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ ៥. អនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្ដីពីសារពើពន្ធ ៦. អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្ដីពីពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ ៧. បន្ថយការចំណាយរបស់រដ្ឋបាលសារពើ-ពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ក្រសួង ធ្វើឱ្យមានភាពសាមញ្ញ ចំពោះតម្រូវការផ្សេងៗ និងបន្ថយចំណាយរបស់អ្នកជាប់ពន្ធ ៨.បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព ៩.បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារ ដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន[3]។ ផ្នែកនេះក៏ចូលរួមអនុវត្តដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ[4]។ ជាលទ្ធផល អគ្គនាយកដ្ឋានបានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

### ២.១.១. ការគៀរគរចំណូលសារពើពន្ធ

- ការគ្រប់គ្រងចំណូលពន្ធដារកម្ពុជា
  - សរុបក្នុងឆមាសទី១ ឆ្នាំ២០២២ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្ដែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ៧ ៩៨០,៥៧ ប៊ីលានរៀល (ប្រមាណជា ១ ៩៧០,៥១ លានដុល្លារ) ស្មើនឹង ៦៩,៨៩% នៃផែនការច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២១ ឃើញថាកើនឡើងចំនួន ១ ៨៣៣,៥៩ ប៊ីលានរៀល (ប្រមាណជា ៤៥២,៧៤ លានដុល្លារ) ស្មើនឹង ២៩,៨៧%
  - ក្នុងឆមាសទី១ ឆ្នាំ២០២២នេះ ចំណូលពន្ធ-អាករទៅតាមប្រភេទពន្ធ និងតាមសកម្មភាពអាជីវកម្មសំខាន់ៗ ឃើញថាមានលម្អៀងធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោម÷

**តារាងចំណូលតាមប្រភេទពន្ធក្នុងឆមាសទី១ ឆ្នាំ២០២២**

| ប្រភេទពន្ធសំខាន់ៗ | ឆមាសទី១ ឆ្នាំ ២០២១ | ឆមាសទី១ ឆ្នាំ ២០២២ | លម្អៀង | | អត្រាកំណើន ឬថយចុះ |
|---|---|---|---|---|---|
| | ឯកតា ÷ ប៊ីលានរៀល | | ប៊ីលានរៀល | លានដុល្លារ | |
| អាករលើតម្លៃបន្ថែម | ១ ២០១,២៩ | ១ ៦០២,២០ | ៤០០,៩១ | ៩៨,៩៩ | ៣៣,៣៧% |
| ពន្ធលើប្រាក់ចំណូល | ២ ៥៩៧,៩៦ | ៣ ៣០៤,៣៨ | ៧០៦,៤១ | ១៧៤,៤២ | ២៧,១៩% |
| អាករពិសេស | ៤៣១,៨៩ | ៥៧៨,៧៩ | ១៤៦,៩០ | ៣៦,២៧ | ៣៤,០១% |
| ពន្ធលើប្រាក់បៀវត្ស | ៤៧៨,១៣ | ៥៩៨,៤៥ | ១២០,៣២ | ២៩,៧១ | ២៥,១៦% |
| ពន្ធប្រថាប់ត្រា | ៣០៥,០៤ | ៤៣២,០៦ | ១២៧,០២ | ៣១,៣៦ | ៤១,៦៤% |
| ពន្ធលើឈ្នួលផ្ទះនិងដី | ៩,២៥ | ១០,១៩ | ០,៩៣ | ០,២៣ | ១០,១២% |

[3] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[4] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**តារាងចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ ក្នុងឆមាសទី១ ឆ្នាំ២០២២**

*(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online ថ្មីរបស់អគ្គនាយកដ្ឋានពន្ធដារ)*

| សកម្មភាពអាជីវកម្ម | ឆមាសទី១ ឆ្នាំ២០២១ | ឆមាសទី១ ឆ្នាំ២០២២ | លម្អៀង | | អត្រា កំណើន ឬ ថយចុះ |
|---|---|---|---|---|---|
| | ឯកតា ÷ ប៊ីលានរៀល | | ប៊ីលានរៀល | លាន ដុល្លារ | |
| នីហរ័ណ អាហរ័ណ (រួមបញ្ចូលការលក់ផលិតផលតេលសិលា) | ១ ២៦២,៥៨ | ១ ១៥០,៨០ | (១១១,៧៨) | (២៧,៦០) | (៨,៨៥%) |
| សេវាហិរញ្ញវត្ថុ និងធានារ៉ាប់រង | ១ ៥៧២,៤៤ | ២០០០,៦៣ | ៤២៨,១៨ | ១០៥,៧២ | ២៧,២៣% |
| កសិកម្ម រុក្ខប្រមាញ់ និងនេសាទ | ២៦,២៩ | ៤៥,០០ | ១៨,៧១ | ៤,៦២ | ៧១,១៦% |
| ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ | ៣៥,២៥ | ២៦,៣៥ | (៨,៩០) | (២,២០) | (២៥,២៥%) |
| កម្មន្តសាល | ៩២៧,៥០ | ១ ៧១៣,០៩ | ៧៨៥,៥៩ | ១៩៣,៩៧ | ៨៤,៧០% |
| សកម្មភាពអចលនវត្ថុ | ៤១០,០៨ | ៥១០,៨០ | ២០០,៧១ | ២៤,៨៦ | ២៤,៥៦% |
| ការដឹកជញ្ជូន និងការស្តុកទុក | ២៣១,៨១ | ៣៣០,០៥ | ៩៨,២៣ | ២៤,២៥ | ៤២,៣៨% |
| ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | ៣៤៨,១១ | ៤៧៩,៣៦ | ១៣១,២៥ | ៣២,៤១ | ៣៧,៧០% |
| ការអប់រំ | ២៩,៨០ | ៣៦,២១ | ៦,៤០ | ១,៥៨ | ២១,៤៩% |
| សេវាកម្មស្នាក់នៅ និងអាហារ | ៧៤,៧២ | ១១៦,០០ | ៤១,២៧ | ១០,១៩ | ៥៥,២៤% |
| ការសាងសង់ | ៣២០,៨២ | ៣៧៤,៤៨ | ៥៣,៦៦ | ១៣,២៥ | ១៦,៧៣% |
| ការផ្គត់ផ្គង់អគ្គិសនី ចំហាយទឹក និងខ្យល់ត្រជាក់ | ១៩៧,៣៧ | ២៣៣,៦៩ | ៣៦,៣៣ | ៨,៩៧ | ១៨,៤១% |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស | ១៦៣,៧៧ | ២៤៣,៧៧ | ៨០,០០ | ១៩,៧៥ | ៤៨,៨៥% |
| សកម្មភាពរដ្ឋបាលនិងគាំទ្រផ្សេងទៀត | ៤៤,០៧ | ៦៦,១១ | ២២,០៣ | ៥,៤៤ | ៥០,០០% |
| សកម្មភាពសេវាកម្មផ្សេងទៀត | ២៩,៩៦ | ៣៤,៦០ | ៤,៦៤ | ១,១៤ | ១៥,៤៧% |

- ឆមាសទី១ ឆ្នាំ២០២២ នេះ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលប្រមូលតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបែងចែកតាមប្រភេទអ្នកជាប់ពន្ធ ដូចខាងក្រោម÷
  - អ្នកជាប់ពន្ធធំ ចំនួន ៦ ៣០៥,៨១ ប៊ីលានរៀល (ប្រមាណជា ១ ៥៥៧,០០ លានដុល្លារ) ស្មើនឹង ៧៩,០១% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ចំណូលតាមប្រភេទអ្នកជាប់ពន្ធធំកើនឡើងចំនួន១ ៤៦៤,៦៩ ប៊ីលានរៀល (ប្រមាណជា ៣៦១,៦៥ លានដុល្លារ) ស្មើនឹង ៣០,២៦%
  - អ្នកជាប់ពន្ធមធ្យម ចំនួន ១ ១១៣,២៣ ប៊ីលានរៀល (ប្រមាណជា ២៧៤,៨៧ លានដុល្លារ) ស្មើនឹង ១៣,៩៥% ធៀបនឹងចំណូលពន្ធ-អាករសរុបហើយប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ចំណូលតាមប្រភេទអ្នកជាប់ពន្ធមធ្យមកើនឡើងចំនួន ២២៤,៣៨ ប៊ីលានរៀល (ប្រមាណជា ៥៥,៤០ លានដុល្លារ) ស្មើនឹង ២៥,២៤%
  - អ្នកជាប់ពន្ធតូច ចំនួន ៣២,៥៥ ប៊ីលានរៀល (ប្រមាណជា ៨,០៤ លានដុល្លារ) ស្មើនឹង ០,៤១% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ចំណូលតាមប្រភេទអ្នកជាប់ពន្ធតូចកើនឡើងចំនួន ៧,១៨ ប៊ីលានរៀល (ប្រមាណជា ១,៧៧ លានដុល្លារ) ស្មើនឹង ២៨,២៩%

        - ផ្សេងៗ (ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ) ចំនួន ៥២៨,៩៧ ប៊ីលានរៀល (ប្រមាណជា ១៣០,៦១ លានដុល្លារ) ស្មើនឹង ៦,៦៣% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ចំណូលពន្ធផ្សេងៗកើនឡើងចំនួន ១៤៤,១៣ ប៊ីលានរៀល (ប្រមាណជា ៣៥,៥៨ លានដុល្លារ) ស្មើនឹង ៣៧,៤៥%
    - ការចុះបញ្ជីពន្ធដារ៖ ឆមាសទី១ ឆ្នាំ២០២២ បានពិនិត្យនិងអនុម័តលើឯកសារស្នើសុំចុះបញ្ជីពន្ធដារចំនួន ៦ ០៦០ សហគ្រាស(ពន្ធធំ ៣៤៨ ពន្ធមធ្យម ៣ ១៧៦ ពន្ធតូច ២ ៥៣៦) ដែលមានលម្អិតដូចខាងក្រោម៖
        - សហគ្រាសបានចុះបញ្ជីជោគជ័យចំនួន ៥ ១៩៨ សហគ្រាស(ពន្ធធំ ៣២៧ ពន្ធមធ្យម ២ ៥៩៥ ពន្ធតូច ២ ២៧៦) ក្នុងនោះតាមថ្នាលចំនួន ៤ ៥៥០ សហគ្រាស(ពន្ធធំ ២១០ ពន្ធមធ្យម ២ ២៧៦ ពន្ធតូច ២ ០៦៤)
        - សហគ្រាសត្រូវបានកំណត់ថាមានហានិភ័យចំនួន ៨៦២ សហគ្រាស(ពន្ធធំ ២១ ពន្ធមធ្យម ៥៨១ ពន្ធតូច ២៦០) ក្នុងនោះតាមថ្នាលចំនួន ៧៦០ សហគ្រាស (ពន្ធធំ ២១ ពន្ធមធ្យម ៤៩៥ ពន្ធតូច ២៤៤) ដោយបានបដិសេធការចុះបញ្ជីចំនួន ២២០ សហគ្រាស និងអនុម័តបញ្ជូនពិនិត្យបន្ថែមចំនួន ៦៤២ សហគ្រាស
        - គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២២ ឯកសារសល់យោងចុងគ្រាមានចំនួន ៤៥៤ សហគ្រាស ក្នុងនោះតាមថ្នាលចំនួន ២៩៨ សហគ្រាស
  - ឆមាសទី១ ឆ្នាំ២០២២ នេះ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសសរុបបានចំនួន ៥ ៧៥៩ ករណី មានប្រាក់ពន្ធចំនួន ៧ ៣៥៦,៧០ ប៊ីលានរៀល (ប្រមាណជា ១ ៩១៦,៤៧ លានដុល្លារ)។ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុង ឆ្នាំ២០២១ ឃើញថាការធ្វើសវនកម្មក្នុងឆមាសទី១ ឆ្នាំ២០២២ គឺមានការកើនឡើងចំនួន ១ ៨៣៣ ករណី (ស្មើនឹង ៤៦,៧០%) និងមានប្រាក់ពន្ធកើនឡើង ចំនួន ៣ ០១២,៣០ ប៊ីលានរៀល (ប្រមាណ ៧៤៣,៧៩ លានដុល្លារ) ស្មើនឹង ៦៩,៣០%
  - ឆមាសទី១ ឆ្នាំ២០២២ បំណុលពន្ធប្រមូលបានមានចំនួន ៥៨១ ១៧៩ លានរៀល(ប្រមាណជា ១៤៣,៥០ លានដុល្លារ) បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ មានចំនួន ៤៩២ ៤៨៣ លានរៀល គឺមានការកើនឡើងចំនួន ៨៨ ៦៩៦ លានរៀល (ប្រមាណជា ២១,៩០ លានដុល្លារ) ស្មើនឹង ១៨,០១%។ សម្គាល់៖ តួលេខបំណុលពន្ធទារបានមានការកែតម្រូវឡើងវិញ និងកត់ត្រាបន្ថែមនូវតួលេខបំណុលពន្ធទារបានក្នុងខែមករា-ឧសភាកន្លងមក ២៦ ៦៨៩ លានរៀល ដោយអ្នកជាប់ពន្ធមិនបានយកបង្កាន់ដៃទូទាត់ប្រាក់ពន្ធទៅប្រកាសនៅអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធដើម្បីកត់ត្រា
- ការគ្រប់គ្រងចំណូលគយ និងរដ្ឋាករកម្ពុជា
    - ឆមាសទី១ ឆ្នាំ២០២២ អគរ ប្រមូលចំណូលបានចំនួន ៥ ២៥៩,៥២ ប៊ីលានរៀល ឬ ១ ២៩៥,៤៤ លានដុល្លារអាមេរិក ត្រូវជាប្រមាណ ៥០,១៨% នៃផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ កើនឡើង ៥៦៣,៧១ ប៊ីលានរៀល ឬ ១៣៨,៨៣ លានដុល្លារអាមេរិក ត្រូវជាប្រមាណ ១២% បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១។ ទន្ទឹមនេះ តួលេខកត់ត្រាដោយរតនាគារជាតិមានចំនួន ៥ ១៥២,៥៤ ប៊ីលានរៀល ឬ ១ ២៦៩,១២ លានដុល្លារអាមេរិក ត្រូវជា ៤៩,១៦% នៃផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១ ចំណូលកត់ត្រាដោយរតនាគារជាតិក្នុងឆមាសទី ១ ឆ្នាំ២០២២ កើនឡើង ៧២៤,៦៤ ប៊ីលានរៀល ឬ ១៧៨,៤៧ លានដុល្លារអាមេរិក ត្រូវជា ១៦,៣៧%

- ចំណូលតាមប្រភេទពន្ធនិងអាករ

**តារាងប្រៀបធៀបចំណូលតាមប្រភេទពន្ធនិងអាករ ក្នុងឆមាសទី១ ឆ្នាំ២០២១ និងឆ្នាំ២០២២**

| ល.រ | ប្រភេទពន្ធនិងអាករ | ឆមាសទី១ ឆ្នាំ២០២១ | ឆមាសទី១ ឆ្នាំ២០២២ | ការប្រៀបធៀប | |
|---|---|---|---|---|---|
| | | ប៊ីលានរៀល | ប៊ីលានរៀល | ប៊ីលានរៀល | ភាគរយ |
| ១ | ពន្ធគយ (ពន្ធនាំចូល) | ៨៤៧,៦៣ | ៩៨៩,៨៤ | ១៤២,២១ | ១៦,៧៨% |
| ២ | អាករនាំចេញ | ១៩,៧១ | ២៥,២២ | ៥,៥០ | ២៧,៩២% |
| ៣ | អាករពិសេស (របបនាំចូល) | ១ ៧៦៥,០២ | ១ ៩៧៧,៦៦ | ២១២,៦៤ | ១២,០៥% |
| ៤ | អាករលើតម្លៃបន្ថែម VAT | ១ ៧៧៥,០១ | ១ ៩៩៦,០៥ | ២២១,០៤ | ១២,៤៥% |
| ៥ | អាករបន្ថែមលើផលិតផលប្រេងកាត (AT)* | ២១៤,០១ | ១៨៩,៤០ | -២៤,៦១ | -១១,៥០% |
| ៦ | ផ្សេងៗទៀត | ៧៤,៤២ | ៨១,៣៥ | ៦,៩៣ | ៩,៣១% |
| សរុប | | ៤ ៦៩៥,៨០ | ៥ ២៥៩,៥២ | ៥៦៣,៧១ | ១២,០០% |

**ក្រាហ្វិកប្រៀបធៀបចំណូលតាមប្រភេទពន្ធនិងអាករ ក្នុងឆមាសទី១ ឆ្នាំ២០២១ និងឆ្នាំ២០២២**




- ចំណូលតាមក្រុមទំនិញ

**ក្រាហ្វិកប្រៀបធៀបចំណូលតាមក្រុមទំនិញក្នុងឆមាសទី១ ឆ្នាំ២០២១ និងឆ្នាំ២០២២**




- ឆមាសទី១ ឆ្នាំ២០២២ ពន្ធនិងអាករជាបន្ទុករបស់រដ្ឋមានចំនួន៧ ២០០,១៤ ប៊ីលានរៀល ឬ ១ ៧៧៣,៣២ លានដុល្លារអាមេរិកកើនឡើង ១ ៤០៤,១៩ ប៊ីលានរៀល ឬ ៣៤៥,៨២ លានដុល្លារអាមេរិក ត្រូវជាប្រមាណ ២៤,២៣% បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១។ក្នុងនោះ ពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុង

វិស័យវិនិយោគកាត់ដេរចំនួន ៣ ៥១៧,៦២ ប៊ីលានរៀល ឬស្មើនឹង ៤៨,៨៦% នៃពន្ធនិងអាករជាបន្ទុករបស់រដ្ឋសរុប កើនឡើង ៤៤៩,៦៥ ប៊ីលានរៀល ឬ ១៤,៦៦% ប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១។ ពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងវិស័យវិនិយោគមិនមែនកាត់ដេរចំនួន ២ ៦៤៧,០៥ ប៊ីលានរៀល ឬប្រមាណ ៣៦,៧៦% នៃពន្ធនិងអាករជាបន្ទុករបស់រដ្ឋសរុប កើនឡើង ៦១៤,៨១ ប៊ីលានរៀល ឬ ៣០,២៥% ប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១។ ទន្ទឹមនេះ មុខសញ្ញាផ្សេងទៀតដូចជា ក្រសួង-ស្ថាប័នរដ្ឋ អង្គការ ស្ថានទូត និងជំនួយបរទេសជាដើម មានចំនួន ១ ០៣៥,៤៧ ប៊ីលានរៀល ឬប្រមាណ ១៤,៣៨% នៃពន្ធនិងអាករជាបន្ទុករបស់រដ្ឋសរុប កើនឡើង ៣៣៩,៦៩ ប៊ីលានរៀល ឬ ៤៨,៨២% ប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១។ ជាការកត់សម្គាល់ ប្រាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋនេះ មានទំហំប្រមាណ ១៣៦,៩០% នៃចំណូលពន្ធនិងអាករដែលប្រមូលបានក្នុងឆមាសទី១ ឆ្នាំ២០២២

**តារាងប្រៀបធៀបពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងឆមាសទី១ ឆ្នាំ២០២១ និងឆ្នាំ២០២២**

| ល.រ | ប្រភេទ ពន្ធនិងអាករជាបន្ទុករបស់រដ្ឋ | ឆមាសទី១ ឆ្នាំ២០២១ | ឆមាសទី១ ឆ្នាំ២០២២ | ការប្រៀបធៀប | | សមាសភាគ |
|---|---|---|---|---|---|---|
| | | ប៊ីលានរៀល | ប៊ីលានរៀល | ប៊ីលានរៀល | ភាគរយ | |
| ១ | វិនិយោគកាត់ដេរ | ៣ ០៦៧,៩៧ | ៣ ៥១៧,៦២ | ៤៤៩,៦៥ | ១៤,៦៦% | *៤៨,៨៦%* |
| ២ | វិនិយោគមិនមែនកាត់ដេរ | ២ ០៣២,២៤ | ២ ៦៤៧,០៥ | ៦១៤,៨១ | ៣០,២៥% | *៣៦,៧៦%* |
| ៣ | បន្ទុករបស់រដ្ឋផ្សេងទៀត* | ៦៩៥,៧៨ | ១ ០៣៥,៤៧ | ៣៣៩,៦៩ | ៤៨,៨២% | *១៤,៣៨%* |
| | សរុប | ៥ ៧៩៥,៩៩ | ៧ ២០០,១៤ | ១ ៤០៤,១៥ | ២៤,២៣% | |

**បន្ទុករបស់រដ្ឋផ្សេងទៀត រួមមាន ក្រសួង-ស្ថាប័នរដ្ឋ អង្គការ ស្ថានទូត និងជំនួយបរទេស ជាដើម*

**ក្រាហ្វិកប្រៀបធៀបពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងឆមាសទី១ ឆ្នាំ២០២១ និងឆ្នាំ២០២២**




- ក្នុងឆមាសទី១ ឆ្នាំ២០២២ ការបាត់បង់ចំណូលពន្ធគយដោយការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមាន ៧៥៧,៧១ ប៊ីលានរៀល ឬស្មើនឹង ១៨៦,៦១ លានដុល្លារអាមេរិក កើនឡើង ៥១,៨២ ប៊ីលានរៀល ត្រូវជា ៧,៣៤% បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១




- ឆមាសទី១ ឆ្នាំ២០២២ ផលិតផលក្នុងស្រុកជំនួសការនាំចូលសំខាន់ៗ រួមមាន ស្រាបៀរ ស៊ីម៉ង់ត៍ ភេសជ្ជៈ បារី និងយានយន្ត។ ដោយផ្អែកលើទិន្នន័យបរិមាណផលិតកម្មក្នុងត្រីមាសទី១ ឆ្នាំ២០២២ ដែលផ្តល់ដោយអគ្គនាយកដ្ឋានពន្ធដារ គួបផ្សំនឹងទិន្នន័យដែលទទួលបានពីវិនិយោគិនពាក់ព័ន្ធ អគរ បានធ្វើការប៉ាន់ស្មានទំហំនៃការបាត់បង់ចំណូលពន្ធនិងអាករនាំចូល ពីមុខទំនិញទាំងអស់ខាងលើ ឃើញថាអាចមានទំហំប្រមាណ ៥២៦,៧៣ លានដុល្លារអាមេរិក។ ក្នុងនោះ ផលប៉ះពាល់ចំណូលពីការផ្គុំដំឡើងរថយន្ត ទោចក្រយានយន្ត និងត្រីចក្រយានយន្ត មានទំហំប្រមាណ ៨៥,២៨ លានដុល្លារអាមេរិក

**តារាងប៉ាន់ស្មានប្រាក់ពន្ធនិងអាករបាត់បង់ពីផលិតកម្មក្នុងស្រុកសំខាន់ៗជំនួសការនាំចូល ក្នុងឆមាសទី១ ឆ្នាំ២០២២**

| ល.រ | ប្រភេទផលិតផល | ប្រាក់ពន្ធអាករបាត់បង់ (លានដុល្លារអាមេរិក) |
|---|---|---|
| I | ផលិតកម្មក្នុងស្រុកសំខាន់ៗជំនួសការនាំចូល | ៤៤១,៤៥ |
| ១ | ស្រាបៀរ | ២៣៧,៥៦ |
| ២ | ស៊ីម៉ង់ត៍ | ១០១,៨៥ |
| ៣ | ភេសជ្ជៈគ្មានជាតិស្រា | ៨៤,៦២ |
| ៤ | បារី | ១៧,៤២ |
| II | ការដំឡើងយានយន្តក្នុងស្រុក | ៨៥,២៨ |
| ១ | ការដំឡើងរថយន្ត | ៧,៤៥ |
| ២ | ការដំឡើងទោចក្រយានយន្ត | ៧៤,៤៧ |
| ៣ | ការដំឡើងត្រីចក្រយានយន្ត | ៣,៣៦ |
| | សរុប | ៥២៦,៧៣ |

- ក្នុងឆមាសទី១ ឆ្នាំ២០២២ ផលប៉ះពាល់ពីគោលនយោបាយបញ្ចុះថ្លៃអគ្គិសនីនេះ មានទំហំសរុបប្រមាណ ៣៦,៦០ លានដុល្លារអាមេរិក

- ទំហំពាណិជ្ជកម្មនៃការនាំចូល៖ ទំហំពាណិជ្ជកម្មនៃការនាំចូលសរុបដោយមិនរាប់បញ្ចូលនូវការនាំចូលមាស ក្នុងឆមាសទី១ ឆ្នាំ២០២២ មានតម្លៃសរុប ១៣ ០១១,៤៣ លានដុល្លារអាមេរិក កើនឡើង ២ ២៩៥,៩៥ លានដុល្លារអាមេរិក ឬ ២១,៤៣% បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១
- ទំហំពាណិជ្ជកម្មនៃការនាំចេញ៖ ទំហំពាណិជ្ជកម្មនៃការនាំចេញសរុបក្នុងឆមាសទី១ ឆ្នាំ២០២២ មានតម្លៃសរុប ១១ ៣៤៣,៣៣ លានដុល្លារអាមេរិក (មិនគិតការនាំចេញមាសបរទេស) កើនឡើង ២ ៩១២,៨៨ លានដុល្លារអាមេរិក ត្រូវជា ៣៤,៥៥% បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១
- ឆមាសទី១ ឆ្នាំ២០២២ អគរ បានបង្ក្រាបបទល្មើសរត់គេចពន្ធចំនួន ១៥ ៦៣១ ករណី រួមមាន ករណីធំ ៤៤៥ និងករណីតូច ១៥ ១៨៦។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២១ ចំនួនករណីដែលបង្ក្រាបបានក្នុងឆមាសទី១ ឆ្នាំ២០២២ នេះ កើនឡើង ៧ ៤៥៦ ករណី ឬ ៩១,២០%។ ទន្ទឹមនេះ អគរ បានដោះស្រាយកំណត់ហេតុបទល្មើសគយរួចចំនួន ១៥ ៤០៨ ករណី ដោយប្រមូលបានប្រាក់ពន្ធអាករនិងពិន័យចំនួន ៧២,៩៨ ប៊ីលានរៀល។

**២.១.២. ការគៀរគរចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ**

- ការគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរដ្ឋ
  - បានចុះបេសកកម្មទៅខេត្តព្រះសីហនុ ដើម្បីចូលរួមកិច្ចប្រជុំពិនិត្យ និងវាយតម្លៃជាក់ស្តែងលើករណីសំណើដោះដូរទីតាំងវិទ្យុ របស់មន្ទីរព័ត៌មានខេត្តព្រះសីហនុ
  - បានចុះបេសកកម្មទៅខេត្តកំពង់ស្ពឺ ដើម្បីចូលរួមក្នុងគណៈកម្មការចម្រុះចុះពិនិត្យ និងវាយតម្លៃគម្រោងស្នើសុំវិនិយោគផ្សារនៅខេត្តកំពង់ស្ពឺ
  - បានចុះបេសកកម្មទៅខេត្តកណ្តាល ដើម្បីចូលរួមក្នុងគណៈកម្មការចម្រុះចុះពិនិត្យ និងសិក្សាវាយតម្លៃ និងធ្វើអាជីវកម្មកំពង់ចម្លងនៅខេត្តកណ្តាល
  - បានចុះបេសកកម្មទៅខេត្តកែប ដើម្បីចូលរួមក្នុងគណៈកម្មការចម្រុះចុះពិនិត្យ និងវាយតម្លៃគម្រោងដាក់ទុនវិនិយោគសាងសង់មណ្ឌលកម្សាន្ត និងអភិវឌ្ឍបរិវេណឆ្នេរ ខេត្តកែប
  - បានបូកសរុបរបាយការណ៍ភាសុីគ្រប់ប្រភេទ ប្រចាំឆមាសទី១ ឆ្នាំ២០២១ របស់រាជធានី-ខេត្ត ទូទាំងប្រទេស
  - បានចុះពិនិត្យ សិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានអំពីការធ្វើអាជីវកម្មរ៉ែសំណង់ នៅខេត្តកណ្តាល
  - បានចូលរួមពិគ្រោះថ្លៃឈ្នួលដីឯកជនរបស់រដ្ឋ និងរៀបចំកិច្ចសន្យាជួលដីសម្រាបគម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសស្ថិតនៅឧទ្យានជាតិបុទុមសាគរ ខេត្តកោះកុង របស់ក្រុមហ៊ុន១
  - បានចុះបេសកកម្មទៅខេត្តកណ្តាល ដើម្បីចុះពិនិត្យ សិក្សាស្រាវជ្រាវ និងប្រមូលពតិមានអំពីការធ្វើអាជីវកម្មរ៉ែសំណង់ នៅខេត្តកណ្តាល និងខេត្តកោះកុង
  - បានចុះបេសកកម្មទៅខេត្តកំពត ដើម្បីពិនិត្យវាយតម្លៃលើសំណើសុំទិញផ្តាច់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន១ ស្ថិតនៅខេត្តកំពត
- ការគ្រប់គ្រងចំណូលសាធារណៈ
  - បានបើកផ្តល់បង្កាន់ដៃបង់ប្រាក់សរុបចំនួន ១១៨ ៤១៥ក្បាល ក្នុងនោះសម្រាប់ការប្រើប្រាស់ប្រមូលចំណូលនៅរដ្ឋបាលថ្នាក់ជាតិចំនួន ១៦ ៦០៥ ក្បាល និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ១០១ ៨១០ក្បាល
  - បានបើកផ្តល់ទិដ្ឋាការស្អិតជូនក្រសួងមហាផ្ទៃ សរុបចំនួន ១២០ ០០០សន្លឹក

- ការប្រមូលចំណូលក្នុងខែមករា ឆ្នាំ២០២២សម្រេចបាន ៣១០ ៨៣៤,៤ លានរៀល ស្មើនឹង ២៦,២% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២។ ចំពោះការប្រមូលចំណូលប្រចាំឆ្នាំ២០២១ សម្រេចបាន ១ ១៣៩ ៧០៣,៥ លានរៀល ស្មើនឹង ៨៤,៧% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១
- គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ទើបទទួលបានរបាយការណ៍ចំណូលប្រចាំខែឧសភា ឆ្នាំ២០២២ របស់ក្រសួង ស្ថាប័ន បានចំនួន ២១ នៅខ្វះចំនួន ១
- បានចេញលិខិតពិនិត្យបញ្ជាក់ស្ដីពីចំនួនទឹកប្រាក់ចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ ដើម្បីទូទាត់រង្វាន់របស់ក្រសួងចំនួន ១៦ ដែលមានទឹកប្រាក់សរុបចំនួន ៤៦ ៤៥០ ៣៨៥ ៨២៣ រៀល ក្នុងនោះក្រសួងយុត្តិធម៌, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងបរិស្ថាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងទេសចរណ៍ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍

- ការគ្រប់គ្រងចំណូលពីសហគ្រាសសាធារណៈ
  - បានធ្វើគម្រោងផែនការអាជីវកម្ម ៣ឆ្នាំរំកិល ឆ្នាំ២០២២-២០២៤ របស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
  - បានធ្វើគម្រោងផែនការថវិកាសម្រាប់ឆ្នាំ២០២២សហគ្រាសសាធារណៈរួមមាន ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម, អគ្គិសនីកម្ពុជា, មន្ទីរពិសោធន៍សំណង់ និងសាធារណការ
  - បានចូលរួមពិនិត្យ និងពិភាក្សាលើអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកជាគ្រឹះស្ថានសាធារណៈរដ្ឋបាលនិងប្រកាសស្ដីពីការប្រើអតិរេកបានចុះហត្ថលេខាលើកំណត់ទុនគ្រាដំបូងនៅ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំរិតក្រុមការងារអន្តរក្រសួង
  - បានរៀបចំសិក្ខាសាលាស្តីពីការត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការបើកវគ្គបណ្តុះបណ្តាលលម្អិតអំពីប្រព័ន្ធ SARMIS ជូនក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក និងនីតិបុគ្គល សាធារណៈ
- ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
  - បានរៀបចំព្រាងផែនការសកម្មភាពធ្វើប័ណ្ណកម្មសិទ្ធិសម្រាប់ក្រសួង ស្ថាប័ន មន្ទីរ រាជធានី ខេត្ត ក្រុងស្រុក ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈ
  - អនុវត្តយុទ្ធនាការណ៍ចុះផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២១ របស់អាជ្ញាធរកាន់កាប់ និងអង្គភាពប្រើប្រាស់ទាំងអស់ទូទាំងប្រទេស
  - គ្រោងរៀបចំកិច្ចប្រជុំពិភាក្សា ជាមួយក្រុមការងារបច្ចេកទេសនៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាអំពីការធ្វើសមាហរណកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាពត៌មាន SAM ជាមួយប្រព័ន្ធបច្ចេកវិទ្យាពត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
  - បានចូលរួមប្រជុំរៀបចំព្រាងអនុក្រឹត្យស្តីពី វិធាន និងនីតិវិធីលម្អិតនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ

- ការគ្រប់គ្រងចំណូល-បំណុលមិនមែនសារពើពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាពត៌មាន
  - បានពិនិត្យតាមដានការស្នើសុំ និងបានអនុម័តលេខកូដចំណូលចំនួន ០៥កូដ ក្នុងនោះកូដចំណូលពីកាតព្វកិច្ចកាស៊ីណូ ចំនួន០២កូដ និងចំណូលកាព្វកិច្ចឆ្នោតចំនួន ០៣កូដ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - បានពិនិត្យ តាមដានការស្នើសុំ និងបានអនុម័តលេខកូដចំណូលចំនួន ៦កូដ ក្នុងនោះកូដចំណូលពីការជួលចំនួន ០១កូដ និងចំណូលផ្សេងៗចំនួន ០៥កូដ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  - បានធ្វើបច្ចុប្បន្នភាពទិន្នន័យ និងបានបូកសរុបតួលេខចំណូលមិនមិនសារពើពន្ធថ្នាក់ជាតិឆ្នាំ២០២១ (គិតត្រឹមថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២២) ដែលមានចំនួន ១ ៨៩៣ ២២៨,៦៥ លានរៀល ត្រូវជា ៨៦,៦១% ធៀបច្បាប់ឆ្នាំ២០២១
  - បានធ្វើបច្ចុប្បន្នភាពទិន្នន័យ និងបានបូកសរុបតួលេខចំណូលមិនមិនសារពើពន្ធថ្នាក់ជាតិឆ្នាំ២០២២ (គិតត្រឹមថ្ងៃទី១៨ខែមិថុនា ឆ្នាំ២០២២) ដែលមានចំនួន ៦២២ ៥៤៦,២៤ លានរៀល ត្រូវជា ៣២,២៥% ធៀបច្បាប់ឆ្នាំ២០២២
  - បានចុះបំពេញបេសកកម្មទៅខេត្តឧត្តរមានជ័យ, ខេត្តកំពង់ធំ, ខេត្តសៀមរាប, ខេត្តក្រចេះ, ខេត្តស្ទឹងត្រែង, ខេត្តព្រះវិហារ, កំពង់ឆ្នាំង និងខេត្តកំពត ដើម្បីចូលរួមពិនិត្យ និងតាមដានស្ថានភាពស្រូវអង្ករជាមួយតំណាងក្រុមហ៊ុនហ្វ្រីគ្នគ្រេដ។

**២.២. ការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការគ្រប់គ្រងចំណាយសាធារណៈ**

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ។ អគ្គនាយកដ្ឋានថវិកាមានបេសកម្មក្នុងការគ្រប់គ្រងថវិកាជាតិហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋក្នុងគោលដៅធានាឱ្យមានការបែងចែកធនធានថវិការដ្ឋប្រកបដោយប្រសិទ្ធភាព ស័ក្តសិទ្ធិភាព និងចីរភាព[5]។ រីឯ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល បំពេញបេសកកម្មសំខាន់ លើការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋប្រកបដោយប្រសិទ្ធភាព ស័ក្តសិទ្ធិភាព និងចីរភាព[6]។ អគ្គនាយកដ្ឋានរតនាគារជាតិ មានបេសកកម្មសំខាន់លើ ១. ជាបេឡាករ និងគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល ២.គ្រប់គ្រងប្រាក់កាក់របស់រដ្ឋ និងគណនីពិសេសរបស់រតនាគារ ៣. រៀបចំគោលការណ៍និងបទបញ្ញាគណនេយ្យសាធារណៈ ៤.កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី ៥.ធានាតុល្យភាពទូទៅនៃគណនី ៦. តម្រង់ទិសនិងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងបំណុលសាធារណៈ ៧.សហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ៨.កសាងសេចក្តីព្រាងច្បាប់សម្រាប់ទូទាត់ថវិកាប្រចាំឆ្នាំ[7]។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានបេសកកម្មសំខាន់ លើការគ្រប់គ្រងលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់អគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ បំពេញបេសកកម្មលើការគ្រប់គ្រង និងការវិភាជថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា។ អង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនក៏ត្រូវបានអនុវត្តក្នុងផ្នែកនេះផងដែរ។ អង្គភាពនេះជំរុញ សម្របសម្រួល និងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ជាលទ្ធផលអគ្គនាយកដ្ឋាន និងអង្គភាពបានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

---

[5] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[6] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[7] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ២.២.១. ការគ្រប់គ្រង និងការអនុវត្តថវិកា

- ការរៀបចំថវិកា
  - បានចូលរួមជាសមាជិកក្នុងក្រុមការងារអង្កេតការបើកចំហថវិការបស់កម្ពុជា
  - បានចូលរួមជាសមាសភាពដើម្បីធ្វើជាសមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់ធ្វើការសិក្សា លើគោលការណ៍និងកំណត់ជម្រើសជាក់លាក់មួយចំនួនក្នុងការដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់កញ្ចប់ថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុងស្រុកខណ្ឌនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ



ការប្រជុំត្រៀមចរចារថវិកា ឆ្នាំ២០២៣ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

  - បានចូលរួមក្នុងក្រុមការងារជាសមាជិកគណៈកម្មការដើម្បីរៀបចំសន្និសីទអន្តរជាតិជនមានពិការភាពប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកលើកទី៥ ឆ្នាំ២០២៣ ដែលកម្ពុជាជាម្ចាស់ផ្ទះ
  - បានចូលរួមជាសមាសភាពដើម្បីធ្វើជាសមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់ធ្វើការសិក្សាលើគោលការណ៍និងកំណត់ជម្រើសជាក់លាក់មួយចំនួនក្នុងការដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់កញ្ចប់ថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុងស្រុកខណ្ឌនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ( គ.ជ.អ.ប)
- ការអនុវត្តថវិកា
  - ចំណាយចរន្ត
    - អនុក្រឹត្យលេខ៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
    - ប្រកាសលេខ០៩៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រូវបានដាក់ឱ្យអនុវត្ត
    - បានប្រជុំពិភាក្សាលើមាត្រាមួយ ចំនួននៃជំពូកទី៣ ស្តីពីសេចក្តីព្រាងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី
    - ធ្វើជាគ្រូបង្គោល ដើម្បីធ្វើបទឧបទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពី នីតិវិធិអនុវត្តថវិកា សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
    - ប្រជុំ និងពិភាក្សាកម្រិតបច្ចេកទេស លើសូចនាករគន្លឹះលទ្ធផល និងសេចក្តីព្រាងថវិកាក្នុងឆ្នាំ ២០២២ ក្រោមកម្មវិធីកែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
    - ចូលរួមសិក្ខាសាលាផ្សព្វផ្សាយឯកសារស្រាវជ្រាវ ទស្សនាទានស្តីពីនីតិសុខដុមនីយកម្មសវនកម្មនិងអធិការកិច្ច

- ចូលរួមគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយ-ការណ៍វឌ្ឍនភាពប្រចាំត្រីមាស ៣ ឆ្នាំ ២០២១
  - ចំណាយវិនិយោគ
    - នៅក្នុងឆមាសទី១ ឆ្នាំ២០២២ នាយកដ្ឋានវិនិយោគ បានផ្ដល់ធានាចំណាយជំពូក២១ (គម្រោងវិនិយោគផ្ទាល់) ជូនក្រសួងសាធារណការនិងដឹកជញ្ជូន ចំនួន ២៥គម្រោង ក្រសួងអភិវឌ្ឍន៍ជនបទ សរុបចំនួន ១៥ គម្រោង ក្រសួងធនធានទឹក និងឧតុនិយម សរុបចំនួន ០៩ គម្រោង ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ចំនួន ០១ គម្រោង ក្រសួងមហាផ្ទៃ សរុបចំនួន ០៥គម្រោង ក្រសួង ស្ថាប័នផ្សេងៗ ចំនួន ១គម្រោង
    - នៅក្នុងឆមាសទី១ ឆ្នាំ២០២២ បានផ្ដល់ធានាចំណាយជំពូក៦១ (ការងារជួសជុលនិងថែទាំ)ជូនក្រសួងសាធារណការនិងដឹកជញ្ជូន សរុបចំនួន ៤៥ គម្រោង ក្រសួងធនធានទឹកនិងឧតុនិយម សរុបចំនួន ៦៩ គម្រោង
    - ការងារចុះបេសកកម្មពិនិត្យវាយតម្លៃ ប្រគល់ទទួល និង/ឬ បញ្ចប់សុពលភាពគម្រោង ÷ ជំពូក២១ (គម្រោងវិនិយោគផ្ទាល់) ក្រសួងសាធារណការ និងដឹកជញ្ជូនមានចំនួន ៣៨គម្រោង ក្រសួងអភិវឌ្ឍន៍ជនបទមានចំនួន ១១គម្រោង ត្រូវនឹង ១៥ខ្សែផ្លូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ០១ គម្រោង ក្រសួងអប់រំ យុវជន និងកីឡា មានចំនួន ៤គម្រោង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួន ០១គម្រោង ។ដោយឡែក ជំពូក៦១ (ការងារជួសជុលនិងថែទាំ) សរុបចំនួន ៤៨ លើក ស្មើនឹង ៨៣គម្រោង។

**២.២.២. ការគ្រប់គ្រងចំណាយសាធារណៈ**

- ការគ្រប់គ្រងចំណាយសាធារណៈថ្នាក់ជាតិ
  - បានរៀបចំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងរួចរាល់លើសេចក្ដីព្រាងវិសោធនកម្មច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
  - បានពិនិត្យនិងផ្ដល់ទិដ្ឋាការលើឯកសារដេញថ្លៃចំនួន ២២៣គម្រោង និងបានចូលរួមប្រជុំចរចាថ្លៃចំនួន ៣១៣ គម្រោង
  - បានចូលរួមប្រជុំបើកឯកសារដេញថ្លៃ (លើសិទ្ធិ)ចំនួន ១៦១គម្រោង និងបានចូលរួមពិគ្រោះថ្លៃ និងស្ទង់តម្លៃ (ក្រោមសិទ្ធិ)ចំនួន ៥៦១គម្រោង
  - បានត្រួតពិនិត្យលើឯកសារកិច្ចសន្យាចំនួន២៨៩ គម្រោង និងបានប្រគល់កិច្ចសន្យាចំនួន ១២១ គម្រោង
  - បានពិនិត្យការស្នើសុំគោលការណ៍អនុវត្តកិច្ចលទ្ធកម្មដោយឡែក៨០ គម្រោង
  - បានចូលរួមត្រួតពិនិត្យវាយតម្លៃលទ្ធផលការងារ បញ្ចប់សុពលភាព ប្រគល់-ទទួល ទំនិញ សំណង់ និងសេវាកម្ម (លើសិទ្ធិ) ចំនួន ១៣០គម្រោង និង (ក្រោមសិទ្ធិ)ចំនួន ៣០៣គម្រោង
  - បានត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយនៅស្ថាប័នអនុវត្តលទ្ធកម្មថ្នាក់ជាតិចំនួន០៧ និងអង្គភាពថវិកាថ្នាក់កណ្ដាលចំនួន០៦ ស្ថាប័នអនុវត្តលទ្ធកម្មរដ្ឋបាលរាជធានី ខេត្តចំនួន១២ និងអង្គភាពថវិកាថ្នាក់មូលដ្ឋានចំនួន ២៤០នៅស្ថាប័នអនុវត្តលទ្ធកម្មអង្គភាពស្វយ័តចំនួន១៦និងនៅស្ថាប័នអនុវត្តលទ្ធកម្មក្រុងស្រុកខណ្ឌចំនួន២២
  - ថ្នាក់ដឹកនាំក្រសួងបានអនុម័តផែនការលទ្ធកម្មរួចរាល់សរុបចំនួន ៧៦ ឯកសារ ក្រសួងស្ថាប័ន ៣២ ឯកសារ ចំពោះរាជធានី-ខេត្ត ៤០ ឯកសារ

- ហិរញ្ញប្បទានឥតសំណង÷បានចុះកិច្ចព្រមព្រៀងចំនួន៩គម្រោង មានទឹកប្រាក់សរុបប្រមាណចំនួន ១២៧,១៧ លានដុល្លារអាមេរិក ដែលមានដូចខាងក្រោម៖
    - ដៃគូអភិវឌ្ឍន៍ពហុភាគី÷ បានចុះកិច្ចព្រមព្រៀងចំនួន ៥គម្រោង មានទឹកប្រាក់សរុបប្រមាណចំនួន ៣៣,៦២ លានដុល្លារអាមេរិក
    - ដៃគូអភិវឌ្ឍន៍ទ្វេភាគី÷ បានចុះកិច្ចព្រមព្រៀងចំនួន ៤ គម្រោង មានទឹកប្រាក់សរុបប្រមាណចំនួន ៩៣,៥៥ លានដុល្លារអាមេរិក
- ឥណទានសម្បទាន÷ បានចុះកិច្ចព្រមព្រៀងចំនួន ៩គម្រោង ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ៦៣៥,៥៩ លានដុល្លារអាមេរិក សមមូលនឹង ៤៧៤,៤៨ លានអេសដេអ៊ែរ ស្មើនឹង ២៩,៦៥% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (១ ៦០០លាន អេសដេអ៊ែរ) ដែលមានដូចខាងក្រោម៖
    - ដៃគូអភិវឌ្ឍន៍ពហុភាគី÷ បានចុះកិច្ចព្រមព្រៀងចំនួន ៤ គម្រោង ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ២៥០,០៦ លានដុល្លារអាមេរិក សមមូលនឹង ១៨៦,៦៧ លានអេសដេអ៊ែរ ស្មើនឹង ១១,៧% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (១ ៦០០លាន អេសដេអ៊ែរ)




ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជាលេខ ១៤

    - ដៃគូអភិវឌ្ឍន៍ទ្វេភាគី÷ បានចុះកិច្ចព្រមព្រៀងចំនួន ៥គម្រោង ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ៣៨៥,៥៣ លានដុល្លារអាមេរិក សមមូលនឹង ២៨៧,៨១ លានអេសដេអ៊ែរ ស្មើនឹង ១៨% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (១ ៦០០លាន អេសដេអ៊ែរ)
- បានដកសាច់ប្រាក់សរុបចំនួន ៩០៦,២៨ លានដុល្លារអាមេរិក ឬ ប្រមាណ ៣ ៦៧៧,៨៦ ប៊ីលានរៀល ស្មើនឹង ៥១,៩៣% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន÷
    - ហិរញ្ញប្បទានឥតសំណង ÷ បានដកសាច់ប្រាក់សរុបចំនួនប្រមាណ ៥០,៤១ លានដុល្លារអាមេរិក ឬ ប្រមាណ ២០៤,៦១ ប៊ីលានរៀល ស្មើនឹង ២៣,៣៥% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
    - ឥណទានសម្បទាន÷ បានដកសាច់ប្រាក់សរុបចំនួនប្រមាណ ៨៥៥,៨៧ លានដុល្លារអាមេរិក ឬ ប្រមាណ ៣ ៤៧៣,២៤ ប៊ីលានរៀល ស្មើនឹង ៥៥,៩៧% នៃផែនការប្រចាំឆ្នាំ
    - ចំណូល-ចំណាយហិរញ្ញប្បទានក្រៅប្រទេស (ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានដែលពុំឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ)÷ អនុវត្តបានចំនួន ៥២៤,៣១ លានដុល្លារអាមេរិក ឬ ប្រមាណ២ ១៣០,៧៤ ប៊ីលានរៀល ស្មើនឹង ៣៦,៦៥% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (៥ ៨១៣ ៤៨៤លានរៀល)
- បានទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍សរុបចំនួន ៨៩៥,៦ ប៊ីលានរៀល ឬ ប្រមាណ ២២០,៣៤ លានដុល្លារអាមេរិក ៤២,១៧% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២
- បានប្រមូលចំណូលសេវាបំណុលពីឥណទាយិកសរុបចំនួន ៨៩,៥១ ប៊ីលានរៀល ឬ ប្រមាណ ២២,០៥ លានដុល្លារអាមេរិកស្មើនឹង៣៤,៥៥% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២

- ○ តាមការប៉ាន់ស្មាន ដោយគិតបញ្ចូលទាំងបំណុលមរតកកំពុងចរចាដោះស្រាយ គិតត្រឹមដំណាច់ខែមីនា ឆ្នាំ២០២២ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួនប្រមាណ៩ ៧៦៧,១៤ លានដុល្លារអាមេរិក ដែលសុទ្ធតែជាបំណុលសាធារណៈក្រៅប្រទេស(បំណុលសាធារណៈក្នុងប្រទេស ត្រូវបានទូទាត់បញ្ចប់កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០)។ ផ្អែកតាមលទ្ធផលបឋមនៃការវិភាគចីរភាពបំណុលបង្ហាញថាបើទោះជាសេដ្ឋកិច្ចកម្ពុជាកំពុងទទួលរងនូវផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ក្តីក៏ស្ថានភាពបំណុលសាធារណៈនៅតែបន្តរក្សាបាននូវ«ចីរភាព» និង «ហានិភ័យកម្រិតទាប» ដដែល
- ○ ប្រជុំពិភាក្សាអំពីការស្នើសុំរៀបចំបើកគណនីសម្រាប់ទទួលប្រាក់ពន្ធ និងអនុគណនីក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់កិច្ចប្រតិបត្តិការទទួលចំណូលពន្ធលើចំណេញមូលធន ពិន័យ ទោសទណ្ឌ និងប្រាក់រង្វាន់ ព្រមទាំងកម្រងសេវាសាធារណៈសម្រាប់ពន្ធលើចំណេញមូលធន
- ○ ប្រជុំពិភាក្សាអំពីការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងឯកសារឌីជីថលជំនានទី១ ដល់រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ ក្នុងគោលដៅជួយពន្លឿនដល់ការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ
- ○ រៀបចំកិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារប្រចាំត្រីមាសទី១ ដោយមានការចូលរួមពីតំណាងគ្រប់ក្រសួង ស្ថាប័ន និងតំណាងធនាគារពាណិជ្ជដៃគូ
- ○ ពិនិត្យសេចក្តីណែនាំស្តីពីការដាក់ឱ្យក្រសួង ស្ថាប័ន ចំនួន១០ អនុវត្តនីតិវិធីនៃការបើកផ្តល់ប្រាក់បៀវត្សដោយពុំចាំបាច់មានអាណត្តិបើកប្រាក់

- ការគ្រប់គ្រងចំណាយសាធារណៈថ្នាក់ក្រោមជាតិ
  - ○ ដាក់ឱ្យអនុវត្តសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសស្តីពីជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់និងសារាចរណែនាំស្តីពីការជំរុញកិច្ចលទ្ធកម្មឃុំសង្កាត់
  - ○ រៀបចំកិច្ចប្រជុំលើកទី១ ក្រុមការងារចំពោះកិច្ចកំណត់ប្រភពចំណូលសម្រាប់បង្កើនធនធានជូនរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ○ រៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០២៣
  - ○ រៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ក្រោមជាតិ ឆ្នាំ២០២៣-២០២៥
  - ○ រៀបចំប្រកាសស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូល និងបែងចែកឥណទានចំណាយថវិកា ជូនរដ្ឋបាលរាជធានី ខេត្តទាំង២៥ ឆ្នាំ២០២២
  - ○ រៀបចំប្រកាសស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូល និងបែងចែកឥណទានចំណាយថវិកា ជូនរដ្ឋបាលក្រុង ស្រុក ឆ្នាំ២០២២ ទូទាំងប្រទេស
  - ○ ចុះផ្សព្វផ្សាយសារាចរណែនាំការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ○ រៀបចំប្រកាសបន្ថែមឥណទានជូនរដ្ឋបាលក្រុង ស្រុកធានាដោយប្រភព៤% នៃចំណូលសារពើពន្ធរដ្ឋបាលខេត្ត
  - ○ វិភាជន៍ធនធានបន្ថែមជូនរដ្ឋបាលឃុំសង្កាត់ ធានាដោយប្រភព៥% នៃចំណូលសារពើពន្ធរដ្ឋបាលរាជធានី ខេត្ត
  - ○ ដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីខណ្ឌ និងគោលការណ៍ណែនាំការអនុវត្តថវិកាប្រយុទ្ធប្រឆាំងជំងឺអេដស៍ មេរោគអេដស៍ នៅក្នុងរាជធានី ខេត្តគោលដៅទាំង៤

- ចុះសិក្សាដំណើការលទ្ធកម្មឃុំ សង្កាត់ នៅខេត្តកណ្ដាល, សង្កាត់តាខ្មៅ, ឃុំកោះធំ, នៅខេត្តកំពង់ស្ពឺ, សង្កាត់រការធំ និងឃុំត្រពាំងគង
- ចុះពិនិត្យវឌ្ឍនភាពគម្រោងអនុវត្តក្រោមរូបភាពសាងសង់មុន និងទូទាត់ជាក្រោយ នៅខេត្តកំពង់ស្ពឺ, ខេត្តសៀមរាប, ខេត្តកំពង់ធំ, និងខេត្ត ត្បូងឃ្មុំ
- ចុះសិក្សាការអនុវត្តមុខងារ៥៥ នៃការិយាល័យមន្ទីរជំនាញដែលផ្ទេរសមាហរណកម្មទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅក្រុង ស្រុក នៃខេត្តកំពង់ចាម ខេត្តកំពត និងខេត្តក្រចេះ និងរៀបចំប្រកាសបង្កើតក្រុមការងារចំពោះកិច្ចកំណត់ប្រភពចំណូលសម្រាប់បង្កើនធនធានជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ២.២.៣. ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

- គម្រោងប្រតិបត្តិការនិងថែទាំប្រព័ន្ធធារាសាស្ត្រព្រែកប្បាស÷បានរៀបចំរបាយការណ៍ស្ដីពីកិច្ចប្រជុំកម្រិតបច្ចេកទេសស្ដីពីការរៀបចំអភិវឌ្ឍគម្រោងប្រតិបត្តិការ និងថែទាំប្រព័ន្ធធារាសាស្ត្រព្រែកប្បាស ជាមួយតំណាងក្រសួងធនធានទឹក និងឧតុនិយម, និងតំណាង Mekong Water Solution
- គម្រោងការអភិវឌ្ឍអាកាសយានដ្ឋានថ្មីខ្នាតតំបន់ នៅខេត្តមណ្ឌលគីរី÷បានរៀបចំលិខិតទៅកាន់រដ្ឋលេខាធិការដ្ឋានអាកាចរស៊ីវិលស្ដីពីករណីសំណើសុំគោលការណ៍ផ្ដល់កិច្ច អន្តរាគមន៍ ដើម្បីគាំទ្រដល់គម្រោងការអភិវឌ្ឍអាកាសយានដ្ឋានថ្មីខ្នាតតំបន់នៅខេត្តមណ្ឌលគីរី
- បានធ្វើការជាមួយក្រុមហ៊ុនឯកជនលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមួយចំនួន÷
  - គម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលភស្តុភារកម្មក្រុងភ្នំពេញ
  - គម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលភស្តុភារកម្មខេត្តព្រះសីហនុ
  - គម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ។

## ២.៣. ការផ្ដល់សេវាគាំទ្រទូទៅ និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ចំណុច២.៣.១ ត្រូវបានអនុវត្ត និងទទួលខុសត្រូវ ដោយអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។ អគ្គលេខាធិការដ្ឋាន មានបេសកកម្មសំខាន់ៗលើ ១.ការផ្ដល់សេវាគាំទ្រសម្រាប់ប្រក្រតីភាពនៃដំណើរការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២. សម្របសម្រួលការងាររវាងថ្នាក់កណ្ដាល និងអង្គភាពមូលដ្ឋានក្រោមឱវាទក្រសួង ពិសេសមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត ៣. ជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ការបណ្ដុះបណ្ដាលនិង វិក្រឹត្យការ ព័ត៌មាន វិទ្យាបណ្ណសារ[8]។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍បេសកកម្ម សំខាន់លើការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា[9]។ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារសំខាន់លើការបណ្ដុះបណ្ដាល និងវិក្រឹត្យការសមត្ថភាពមន្ត្រីរាជការលើមុខជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[10]។ ចំណែក ២.៣.២. ត្រូវបានអនុវត្ត និងទទួលខុសត្រូវដោយ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលមានបេសកកម្មសំខាន់លើការងារពង្រឹងប្រព័ន្ធគ្រប់គ្រងសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាំមុខក្នុងការអភិវឌ្ឍមុខងារសវកម្មផ្ទៃក្នុង នៅតាមបណ្ដាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ[11]។

---

[8] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[9] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[10] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[11] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដោយឡែក ចំណុច ២.៣.៣. មានបេសកកម្មសំខាន់លើការងារធ្វើអធិការកិច្ច លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើអភិក្រម អធិការកិច្ចផ្អែកលើហានិភ័យ និងអធិការកិច្ចផ្អែកលើករណីសង្ស័យឬបណ្តឹងតវ៉ាជាក់ស្តែង[12]។ ចុងក្រោយ លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានមុខងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាសុវត្ថិភាពនីត្យានុកូលភាព នៃការគ្រប់គ្រងនិងការអភិវឌ្ឍ ប្រកបដោយសង្គតិភាព និងចីរភាព នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ជាលទ្ធផល ក្នុងឆមាសទី១ ឆ្នាំ២០២២ អង្គភាពនីមួយៗ បានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម ÷

**២.៣.១. ការផ្តល់សេវាគាំទ្រទូទៅ**

- គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ បានអនុម័តលើផែនការដោះស្រាយផលប៉ះពាល់លម្អិត DRP នៃគម្រោងអភិវឌ្ឍន៍ក្រុងរបៀង ៤ អនុគម្រោងទីលានចាក់សំរាមខេត្តក្រចេះ និងខេត្តស្ទឹងត្រែង
- ក្រុមការងារកំពុងពិនិត្យ និងរៀបចំផែនការដោះស្រាយផលប៉ះពាល់លម្អិត នៃគម្រោងអភិវឌ្ឍន៍ក្រុងរបៀង ៤ អនុគម្រោងអាងចម្រោះទឹកកខ្វក់នៅខេត្ត កំពង់ចាម
- បានរៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងស្តីពី ស្តង់ដានីតិវិធីប្រតិបត្តិសម្រាប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ដល់មន្ត្រីក្រោមឱវាទនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
- សេចក្តីព្រៀងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ របស់គណៈកម្មការអស្សាមិករនិងអនុគណៈកម្មការអស្សាមិករ ត្រូវបានដាក់ឆ្លងពិគ្រោះយោបល់ ជាមួយអន្តរអគ្គនាយកដ្ឋាន នៃកសហវ និងក្រសួង-ស្ថាប័នពាក់ព័ន្ធរួចរាល់ និងបានបញ្ជូនទៅលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ដើម្បីពិនិត្យ និងផ្តល់យោបល់
- សេចក្តីព្រៀងអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីសម្រាប់អនុវត្តច្បាប់ស្តីពីអស្សាមិករណ៍ ត្រូវបានប្រជុំពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរួចរាល់
- បានប្រមូលឯកសារពាក់ព័ន្ធសម្រាប់សៀវភៅសិក្សាស្តីពីនីតិវិធី និងកិច្ចបញ្ជិកាគណនេយ្យសាធារណៈសម្រាប់ថ្នាក់ក្រោមជាតិ។

**២.៣.២ ការងារសវនកម្មផ្ទៃក្នុង**

- បញ្ជូនរបាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច, តារាងតុល្យភាពគណនីរដ្ឋទេយ្យបុរេប្រទាន, ទិន្នានុប្បវត្តិទូទៅសៀវភៅធំ, តារាងតាមដានស្ថានភាពរដ្ឋទេយ្យបុរេប្រទាន, បញ្ជីបេឡាក្នុងដៃរបស់រដ្ឋទេយ្យករ, បញ្ជីតាមដានប្រាក់របស់រដ្ឋទេយ្យករនៅធនាគារ ប្រចាំខែវិច្ឆិកា ធ្នូ និងប្រចាំឆ្នាំ២០២១ និងប្រចាំខែមករា កុម្ភៈ មីនា មេសា និងខែឧសភា ឆ្នាំ២០២២ ទៅអគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានរតនាគារជាតិ
- បញ្ចប់ការរៀបចំរបាយការណ៍សវនកម្មផ្ទៃក្នុង នៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានថវិកាសម្រាប់ឆ្នាំ២០២១
- បញ្ចប់ការចុះធ្វើសវនកម្មថ្នាក់មូលដ្ឋានសម្រាប់ឆ្នាំ២០២២ នៅខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តកោះកុង ខេត្តបន្ទាយមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តមណ្ឌលគិរី ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តរតនគិរី ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ
- បញ្ចប់លិខិតជំរុញជុំទី១ ឆ្នាំ២០២២ សម្រាប់ការធ្វើសវនកម្ម នៅខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តកោះកុង ខេត្តបន្ទាយមានជ័យ និងខេត្តត្បូងឃ្មុំ

---

[12] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ធ្វើសវនកម្មអនុលោមភាពទៅលើ និយ័តករគណនេយ្យនិងសវនកម្ម និងនិយ័តអាជីវកម្មអចលនវត្ថុនិងបញ្ចាំ បានបញ្ចប់កិច្ចប្រជុំក្រុមសវនករ ដើម្បីត្រៀមចុះធ្វើសវនកម្ម
- សិក្សាអំពីក្របខ័ណ្ឌក្នុងការអនុវត្តការពិនិត្យឡើងវិញទាំងក្របខ័ណ្ឌជាតិ និងអន្តរជាតិ បានរៀបចំសេចក្តីព្រាងរបាយការណ៍បឋម
- បានទទួលការអនុម័តដាក់ឱ្យអនុវត្តលើឧត្តមានុវត្តន៍នៃការគ្រប់គ្រងអនុលោមភាព
- បានដាក់ឱ្យប្រើប្រាស់សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីសវនកម្មការអនុលោមភាព សេចក្តីព្រាងសេចក្តីណែនាំយន្តការ និងនីតិវិធីស្តីពីការធ្វើសវនកម្មអនុលោមភាព សេចក្តីព្រាងទម្រង់បញ្ជីត្រួតពិនិត្យស្តីពីការធ្វើសវនកម្មអនុលោមភាព សេចក្តីព្រាងទម្រង់របាយការណ៍ស្តីពីការធ្វើសវនកម្មអនុលោមភាព សេចក្តីព្រាងសៀវភៅមគ្គុទេសក៍ស្តីពីសវនកម្មផ្ទៃក្នុង។

**២.៣.៣. ការងារអធិការកិច្ច**

- បានដឹកនាំកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំអគ្គាធិការដ្ឋានពិភាក្សាលើសេចក្តីព្រាងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុថ្មី លើជំពូកស្តីពីសវនកម្មនិងអធិការកិច្ច
- បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ដែលបានពិនិត្យនិងកែសម្រួលរួចរាល់
- បានចុះបំពេញបេសកកម្មចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុទៅកាន់គ្រឹះស្ថានសាធារណៈនៅភ្នំពេញនិងបាត់ដំបង, និងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈភូមិភាគតេជោសែនសៀមរាបមន្ទីរពេទ្យព្រះអង្គឌួង,អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍, បេឡាជាតិរបបសន្តិសុខសង្គមកំពង់ផែស្វយ័តភ្នំពេញ, មន្ទីរពិសោធន៍សំណង់និងសាធារណការ, សាកលវិទ្យាល័យស្វាយរៀង, សាកលវិទ្យាល័យបាត់ដំបង, វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង, វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង និងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈភូមិភាគតេជោសែនបាត់ដំបង
- បានចុះបំពេញបេសកកម្មចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា និងបណ្តាអង្គភាពក្រោមចំណុះ
- បានចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុ ការិយបរិច្ឆេទ ២០២០ ទៅកាន់គ្រឹះស្ថានសាធារណៈនៅភ្នំពេញនិងបាត់ដំបង,និងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈភូមិភាគតេជោសែនសៀមរាបមន្ទីរពេទ្យព្រះអង្គឌួង, អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍,បេឡាជាតិរបបសន្តិសុខសង្គមកំពង់ផែស្វយ័តភ្នំពេញ, មន្ទីរពិសោធន៍សំណង់និងសាធារណការ, សាកលវិទ្យាល័យស្វាយរៀង, សាកលវិទ្យាល័យបាត់ដំបង, វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង, វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង និងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈភូមិភាគតេជោសែនបាត់ដំបង
- បានចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុ ការិយបរិច្ឆេទ ២០២០ នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងរ៉ែនិងថាមពល ក្រសួងព័ត៌មាន និងបណ្តាអង្គភាពក្រោមចំណុះ
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមការិយបរិច្ឆេទ២០២១ ទៅកាន់រដ្ឋបាល ខេត្ត សាលាដំបូង និងបណ្តាមន្ទីរជំនាញនៅរាជធានីភ្នំពេញខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងខេត្តព្រៃវែង
- បានបញ្ចប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ការិយបរិច្ឆេទ ២០២០ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍,វិទ្យាស្ថានជាតិកសិកម្មព្រែក

លៀប, ក្រុមហ៊ុនហ្គ្រីនត្រេដ, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងកិច្ចការនារី, វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានបញ្ចប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- បានបញ្ចប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមបណ្តារដ្ឋបាលខេត្ត សាលាដំបូង និងមន្ទីរជំនាញខេត្តនៅខេត្តប៉ៃលិន និងខេត្តកំពង់ស្ពឺ។

**៣.ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ដោយគ្រប់អង្គភាពទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទីចូលរួម អនុវត្ត លើកកម្ពស់ ក្នុងការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈគ្រប់ដំណាក់កាល ដើម្បីឱ្យការងារគ្រប់គ្រងសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ ក្នុងក្រសួង ក៏ដូចជា គ្រប់ក្រសួងស្ថាប័ន កាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ដូចនេះ ផ្នែកទី៣ នេះ ត្រូវបានអនុវត្ត និងទទួលខុសត្រូវ ពីគ្រប់អង្គភាពទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាលទ្ធផល អង្គភាពបានអនុវត្តនិងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

- កែសម្រួលផែនការសកម្មភាពលម្អិត សម្រាប់អនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ ទៅតាមទម្រង់ថ្មី
- រៀបចំកិច្ចប្រជុំពិភាក្សាផែនការពង្រីកអនុវត្តគម្រោង FMIS ជំហានទី៣ ឆ្នាំ២០២១-២០២៥
- រៀបចំប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)
- ប្រជុំពិភាក្សា ដើម្បីកំណត់មុខសញ្ញាចំណាយដែលមានហានិភ័យកម្រិតទី២ និងកម្រិតទី៣ សម្រាប់ជាមូលដ្ឋានក្នុងការសិក្សា និងរៀបចំដាក់ឱ្យអនុវត្តនូវនីតិវិធីតម្រង់ទិសថ្មីតាមប្រព័ន្ធ FMIS



ប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធសាធារណៈ(ថ្មី)
ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០២២

- រៀបចំសេចក្តីព្រាងទស្សនាទានក្របខ័ណ្ឌគុណវឌ្ឍិនៃមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានបន្តពង្រឹងការទូទាត់ចំណាយដែលមានហានិភ័យទាបតាមទម្រង់នីតិវិធីថ្មីក្នុងប្រព័ន្ធ FMIS
- ប្រជុំពិភាក្សាអំពីការរៀបចំអនុវត្តចំណាយពេញលេញក្នុងប្រព័ន្ធ FMIS នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ប្រជុំពិភាក្សា ដើម្បីពិនិត្យលទ្ធភាពកាត់បន្ថយឯកសារ ពីខាងក្រៅ ជំនួសដោយការអនុវត្តនីតិវិធីការងារតាមប្រព័ន្ធទាំងស្រុង ក្នុងក្របខណ្ឌនៃការធ្វើសន្ធានកម្មទិន្នន័យរវាងប្រព័ន្ធ FMIS និងប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- បានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ ប្រចាំឆ្នាំ២០២១ នៃការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣បូក២
- បានធ្វើរបាយការណ៍វឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០២១
- បានចូលរួមកិច្ចប្រជុំពិភាក្សាលើលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥។